ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ២២១៨ ឧស.ទស.សជណ

ថ្ងៃពុធ ២ រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ២០១៨

## សេចក្តីជូនដំណឹង

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានកិត្តិយសសម្រាប់ជូនសាធារណជន រូបវន្តបុគ្គល/នីតិបុគ្គល ទាំងអស់ឱ្យបានជ្រាបថា៖ ក្រសួងសូមធ្វើការកែតម្រូវថ្លៃលក់ទឹកដែលត្រូវដាក់ដេញថ្លៃក្នុងសេចក្តីជូនដំណឹងលេខ ២១៧៨ ឧស.ទស.សជណ ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០១៨ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៃសេចក្តីជូនដំណឹងស្តីពី ការដាក់ដេញថ្លៃជាសាធារណៈសម្រាប់ការជ្រើសរើសអ្នកផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតនៅ ឃុំខ្សែត្រ(៦ភូមិ/៦ភូមិ) និង ឃុំញរ(១៤ភូមិ/១៤ភូមិ) ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង ដូចខាងក្រោម៖

- ថ្លៃលក់ទឹកសម្រាប់ដេញថ្លៃគឺ

  - **ចាប់ពី ០ ដល់ ៣ម៣** ថ្លៃលក់ទឹក **១ ៩០០៛/ម៣**
  - **ចាប់ពី ៤ម៣ ឡើងទៅ** ថ្លៃលក់ទឹកដេញថ្លៃចន្លោះពី **២ ០០០៛/ម៣ ដល់ ២ ២០០៛/ម៣**

សេចក្តីដូចបានជម្រាបជូនខាងលើនេះ សូម សាធារណជន រូបវន្តបុគ្គល/នីតិបុគ្គល ទាំងអស់ជ្រាបជាព័ត៌មាន សេចក្តីជូនដំណឹងនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**ឯក សុនចាន់**

- នាយកដ្ឋានបញ្ញត្តកម្មទឹកស្អាត នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម
  លោក សឿង យុត្តិរ៉ា 092 768 699
- មន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តស្វាយរៀង
  លោក ឡុង សុខុម 017 255 727 / 097 725 5727
- កម្មវិធីការវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ-(3i) 012 819 105
  អ៊ីម៉ែល៖ info@3icambodia.org